00630737



**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ៧៥)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ** / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី *ADVOCATS SANS FRONTIÈRES* FRANCE ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ និង នួន ជា**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គបុរេជំនុំជម្រះ** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម ប្រាក់ គឹមសាន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ន័យ ថុល | លោក Andrew CAYLEY |
| | ចៅក្រម ហួត វុទ្ធី | |
| | ចៅក្រម Catherine MARCHI-UHEL | **ក្រុមមេធាវីការពារក្ដីទាំងអស់** |
| | ចៅក្រម Rowan DOWNING | |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 13 / 12 / 2010
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") សូមដាក់ចម្លើយតបនេះទៅនឹងការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ("ដើមបណ្តឹងរដ្ឋប្បវេណី") *Advocats Sans Frontières France* ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ("ការអង្កេត")[1] ។ ចម្លើយតបនេះនឹងដោះស្រាយលើបញ្ហាជាច្រើន ដែលត្រូវបានលើកឡើងនៅក្នុងសារណាឆ្លើយតបរួម ដែលជាប់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី[2] តាមលំដាប់លំដោយ ដែលត្រូវបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ។

## I. **ការឆ្លើយតបរួម**

១. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងដូចខាងក្រោម:

ក) ការយកមកប្រើប្រាស់ដើម្បីផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភធ្ងន់ធ្ងរយ៉ាងទៅលើអនុសញ្ញាក្រុងហ្សឺណែវ ("ការរំលោភយ៉ាងធ្ងន់ធ្ងរ") មិនរំលោភគោលការណ៍នីត្យានុកូលភាពទេ ។

ខ) ការយកមកប្រើប្រាស់ដើម្បីផ្តន្ទាទោសឧក្រិដ្ឋកម្មជាតិមិនរំលោភលើគោលការណ៍នីត្យានុ-កូលភាពទេ ។

គ) ការយកមកប្រើប្រាស់ដើម្បីផ្តន្ទាទោសសហឧក្រិដ្ឋកម្មរួម ("JCE") ។

ឃ) ការយកមកប្រើប្រាស់ដើម្បីផ្តន្ទាទោសការទទួលខុសត្រូវជាថ្នាក់លើ ។

ង) សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ មិនត្រូវបានគេរំលោភបំពានឡើយ និង

ច) ការលើកលែងទោស និងការមិនជំនុំជម្រះពីរដង *ne bis in idem* មិនបានរារាំងមិនឱ្យ

[1] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៧-០៩-២០១០-អវតក/កសចស (អបជ៧៥) ចម្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី *Advocats Sans Frontières France* ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២ ២០១០ ឯកសារ D427/1/18, ERN: 00630408-00630421។

[2] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៧-០៩-២០១០-អវតក/កសចស (អបជ៧៥) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ D427/1/6, ERN: 00617486-00617631 ("បណ្តឹងឧទ្ធរណ៍")

ជំនុំជម្រះលោក អៀង សារី ឡើយ ។

## II ចម្លើយតប

### ក. ដីកាដំណោះស្រាយរំលោភទៅលើគោលការណ៍នីត្យានុកូលភាព

២. ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងនៅក្នុងកថាខណ្ឌទី៨ ថាភាពអនុវត្តបាននៅ អវតក នៃគោលការណ៍នីត្យានុកូលភាព មានចែងនៅក្នុងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(“ICCPR”) ។ ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងនៅក្នុងកថាខណ្ឌទី៩ ថាគោលការណ៍នេះក៏តម្រូវ “ថាបទល្មើសដែលត្រូវបានចោទប្រកាន់ ត្រូវតែអាចព្យាករបានយ៉ាងគ្រប់គ្រាន់ដោយជនជាប់ចោទ ក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិនៅពេលប្រព្រឹត្តបទល្មើសទាំងនេះ...”[3]។ ដើមបណ្តឹងរដ្ឋប្បវេណីពិតជាត្រឹមត្រូវ ក្នុងការអះអាងថាគោលការណ៍នីត្យានុកូលភាពមានចែងនៅក្នុង ICCPR ដែលត្រូវតែគោរព តែដើមបណ្តឹងរដ្ឋប្បវេណីខកខានមិនបានទទួលស្គាល់ថាគោលការណ៍នីត្យានុកូលភាពនេះមានចែងនៅក្នុងច្បាប់កម្ពុជាដែលពាក់ព័ន្ធទេ នោះមានន័យថាមាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលត្រូវតែគោរពផងដែរ ។ គោលការណ៍ដែលមានចែងនៅក្នុងមាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មានលក្ខណៈតឹងរ៉ឹងជាងគោលការណ៍ដែលមានចែងនៅក្នុង ICCPR[4]។ មិនដូច ICCPR ទេគោលការណ៍នីត្យានុកូលភាពនៅក្នុងមាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មិនអនុញ្ញាតឱ្យមានករណីលើកលែងក្នុងការប្រើប្រាស់ដើម្បីផ្តន្ទាបទល្មើសជាប្រតិសកម្ម ដែលត្រូវបាន “ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ អនុលោមតាមគោលការណ៍ច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ”[5] ។ គោលការណ៍នេះតម្រូវថាដើម្បីអាចផ្តន្ទាទោសបាន បទល្មើសត្រូវមានចែងនៅក្នុងច្បាប់កម្ពុជានៅពេលប្រព្រឹត្ត[6] ។

---

[3] បញ្ជាក់បន្ថែម ។

[4] ដូចខាងលើ នៅកថាខណ្ឌទី ១០៤-១០ ។

[5] ICCPR មាត្រា ១៥ ។

[6] មាត្រា ៦ ចែងថា: ច្បាប់ព្រហ្មទណ្ឌគ្មានអនុភាពជាប្រតិសកម្មទេ គឺថាបទល្មើសណាបានប្រព្រឹត្តមុនបទបញ្ញត្តិរបស់ច្បាប់ បទនោះមិនអាចផ្តន្ទាទោស តាមទោសរបស់ច្បាប់ ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ ។ ប៉ុន្តែ បើច្បាប់នេះលុបចោលបទល្មើស

៣. នៅក្នុងកថាខណ្ឌទី១០ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថាក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ គឺជាច្បាប់ដែលអនុវត្តនៅថ្នាក់ជាតិ ប៉ុន្តែ "នៅកម្រិតអន្តរជាតិវិញ កម្ពុជាផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ គោលការណ៍ទូទៅនៃច្បាប់ និងអនុសញ្ញានានាដែលបានឱ្យសច្ចាប័នរួចហើយ" ។ វាមានលក្ខណៈមិនច្បាស់ថា តើការអះអាងនេះមានន័យយ៉ាងដូម្តេចនោះ ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី មានចេតនាអះអាងថា កម្ពុជាផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ គោលការណ៍ទូទៅនៃច្បាប់ និងអនុសញ្ញានានាដែលបានឱ្យសច្ចាប័នរួច នៅពេលដែលកម្ពុជាកំពុងធ្វើសកម្មភាពក្នុងក្របខណ្ឌអន្តរជាតិ ដូចជានៅដែលកម្ពុជាកំពុងតែធ្វើសកម្មភាពដែលជាផ្នែកមួយនៃមហាសន្និបាតអង្គការសហប្រជាជាតិ នោះការអះអាងបែបនេះពិតជាត្រឹមត្រូវ។ ប៉ុន្តែ ចំនុចនេះមិនមានអ្វីពាក់ព័ន្ធជាមួយកិច្ចការរបស់ អវតក ដែលជាតុលាការជាតិនោះទេ ។

៤. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅក្នុងកថាខណ្ឌទី ១១ ថាមាត្រា ១, ២ និងមាត្រា ២៩ ថ្មីនៃច្បាប់បង្កើត អវតក ដាក់បញ្ចូលក្នុងច្បាប់កម្ពុជានៃឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ ។ សូម្បីតែ កសព បានសារភាពថា[7] ច្បាប់បង្កើត អវតក គឺលក្ខន្តិកៈដែលអាចអនុវត្តបាន ដែលអនុញ្ញាតឱ្យ អវតក អនុវត្តច្បាប់ដែលនៅជាធរមាននៅកម្ពុជាចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ។ គេមិនអាចបង្កើតច្បាប់ជាតិថ្មី ដើម្បីអនុវត្តជាប្រតិសកម្មបានទេ[8] ។

៥. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅក្នុងកថាខណ្ឌទី ១២ ថា កម្ពុជាត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយបទបញ្ញត្តិច្បាប់អន្តរជាតិ ដែលហាមមិនឱ្យកើតឡើងនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ។ កាតព្វកិច្ចរបស់កម្ពុជា ជារដ្ឋមួយ មិនអាចផ្លាស់ប្តូរអង្គហេតុដែលថា អវតក មិនអាចអនុវត្តច្បាប់ដែលមិនមាននៅក្នុងច្បាប់របស់កម្ពុជានៅពេលវេលាដែលពាក់ព័ន្ធនោះទេ ។ កាតព្វកិច្ចនេះមិនជាប់ពាក់ព័ន្ធជាមួយតុលាការទេ[9] ។ បន្ថែមពីលើនេះ កាតព្វកិច្ចហាមមិនឱ្យកើតឡើងនៃឧក្រិដ្ឋកម្ម មិនស្មើនឹង

---

ណាមួយ សម្រាលទោសរបស់បទល្មើសណាមួយវិញ បទល្មើសដែលបានប្រព្រឹត្តមុនច្បាប់ថ្មីនេះ ត្រូវតែបានរួចពីទោស ឬក៏ត្រូវបានសម្រាលទោសនោះ តាមច្បាប់ថ្មីនេះ កុំតែឱ្យបទល្មើសនោះបានទទួលទោសជាស្ថាពររួចទៅហើយ ("បញ្ជាក់បន្ថែម") ។

[7] ចម្លើយតបរបស់ កសព នៅកថាខណ្ឌទី១៣៤ ។

[8] ការធ្វើយ៉ាងដូច្នេះនឹងរំលោភគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់បញ្ញត្តិ (Nullum crimen sine lege) ដែលច្បាប់អន្តរជាតិមិនអាចអនុវត្តដោយផ្ទាល់នៅកម្ពុជាបានទេ ។ សូមមើលកថាខណ្ឌទី ១១-២៥ នៃបណ្តឹងឧទ្ធរណ៍ ។

[9] សូមមើលកថាខណ្ឌទី ១២៦-២៨ នៃបណ្តឹងឧទ្ធរណ៍ ។

កាតព្វកិច្ចផ្ដន្ទាទោសឧក្រិដ្ឋកម្មនោះទេ[10] ។

## ១. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

៦. ដើមបណ្ដឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី១៣រហូតដល់កថាខណ្ឌទី១៥ ថាកម្ពុជាបានឲ្យសច្ចាប័នលើអនុសញ្ញាស្ដីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយការណ៍ដែលថាពុំមានបទបញ្ញត្តិនៃច្បាប់ជាតិក្នុងការធ្វើឲ្យទៅជាបទល្មើសនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក៏មិនអនុញ្ញាតឲ្យចារីរួចផុតពីការផ្ដន្ទាទោសដែរ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានលើកមកសំអាងអនុសញ្ញាក្រុង Vienna ស្ដីពីច្បាប់សន្ធិសញ្ញា ដើម្បីទាញទឡ្ហីករណ៍ថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចយកមកប្រើដើម្បីផ្ដន្ទាទោសបាន ពីព្រោះ "ភាគីមួយមិនអាចយោងបទបញ្ញត្តិនៃច្បាប់ក្នុងស្រុករបស់ខ្លួន ជាយុត្តិកម្មចំពោះការខកខានរបស់ខ្លួនមិនបានគោរពសន្ធិសញ្ញានោះទេ" ។ ជាថ្មីម្ដងទៀត ចំនុចនេះពាក់ព័ន្ធជាមួយកាតព្វកិច្ចរបស់កម្ពុជា ជារដ្ឋមួយ ហើយវាមិនអាចអនុវត្តចំពោះស្ថានភាពបច្ចុប្បន្ននេះបានទេ។ កម្ពុជាមិនត្រូវបានចោទប្រកាន់ចំពោះការខកខានមិនបានគោរពកាតព្វកិច្ចដែលចងដោយសន្ធិសញ្ញាបានទេ ។

៧. ដើមបណ្ដឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី១៦ ថា "តើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចយកមកប្រើដើម្បីផ្ដន្ទាទោសបានដែរ ឬអត់ តាមរយៈការផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬ តាមរយៈច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាទោសដែលត្រូវបានបង្គាប់ស្របតាមអនុសញ្ញានៅក្នុងមាត្រា ៤ នៃច្បាប់បង្កើត អវតក ដែលយោងទៅលើបទបញ្ញត្តិនៃវិធាន ៩៨ នៃវិធានផ្ទៃក្នុង" ។ ការអះអាងនេះមានលក្ខណៈច្បាស់លាស់ ប៉ុន្តែច្បាប់បង្កើត អវតក ដូចដែលបានពន្យល់ពីខាងលើ មិនអាចបង្កើតច្បាប់ថ្មី ដើម្បីយកមកអនុវត្តជាប្រតិសកម្មបានទេ ។ ការដែលថាច្បាប់បង្កើត អវតក អាចបង្កើតទោស[11] នៅឆ្នាំ២០០១ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក៏វាមិនអាចផ្លាស់ប្ដូរអង្គហេតុដែលថាឧក្រិដ្ឋកម្មនេះ មិនអាចផ្ដន្ទាទោសនៅកម្ពុជាចន្លោះ ១៩៧៥-១៩៧៩ ដែរ ។

---

[10] ដូចខាងលើ ។

[11] សូមកត់សំគាល់ថាវិធាន ៩៨ និយាយយោងទៅលើសាលក្រម តែមិនបាននិយាយយោងជាក់លាក់ទៅលើទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ ។

៨. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី១៧ និងកថាខណ្ឌទី១៨ ថាការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាន៍ ត្រូវតែបានដឹង ដោយសារឋានៈនៃទំនៀមទម្លាប់អន្តរជាតិរបស់ទម្រង់នៃការទទួលខុសត្រូវ ការដាក់បញ្ចូលមួយផ្នែករបស់វានៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ។ វាមានលក្ខណៈមិនច្បាស់លាស់ថាហេតុអ្វីបានជាដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ឋានៈនៃទម្រង់នៃការទទួលខុសត្រូវមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬថាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មានអនុភាពលើភាពអាចដឹងបាននៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជាចន្លោះឆ្នាំ ១៩៧៥-១៩៧៩ នោះ ។ វាក៏មានលក្ខណៈមិនច្បាស់លាស់ដូចគ្នាដែរថា តើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា បង្កើតឲ្យមានការទទួលខុសត្រូវដែលអាចព្យាករណ៍បាននៅកម្ពុជាចន្លោះឆ្នាំ ១៩៧៥-១៩៧៩ យ៉ាងដូម្តេច ។ ការផ្តន្ទាទោសដំបូងបំផុតទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូហ្វាន់ដានៅឆ្នាំ១៩៩៨[12] ។

៩. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី១៩ ថា “ការលើកឡើងដែលថាច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនអាចអនុវត្តនៅ អវតក បាន គឺជាការនិយាយគ្មានមូលដ្ឋាន ដោយសារតែការផ្តល់សច្ចាប័នជាសកលទៅលើអនុសញ្ញានានា គោលការណ៍ជាសកលភាពអនុវត្តចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការធ្វើទារុណកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌ និងទំនៀមទម្លាប់អន្តរជាតិ”។ ដើមបណ្តឹងរដ្ឋប្បវេណីហាក់ដូចជាមិនទទួលស្គាល់ការពិតដែលថា អវតក គឺជាតុលាការជាតិមួយ”[13] ។ អវតក មិនមែនជាតុលាការអន្តរជាតិ ដែលអាចអនុវត្តយុត្តាធិការសកលបានទេ ។ ការលើកយកមកសំអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើអត្ថបទរបស់លោក Antonio Cassese ដែលមានចំណងជើងថា *Is the Bell Tolling for Universality? A Plea for a Sensible Notion of Universal Jurisdiction* គឺមានភាពមិនច្បាស់លាស់ ។ មិនមានលេខទំព័រដែលបានយោង ហើយអក្សរក្នុងលេខយោងវិញហាក់ដូចជាមិនពាក់ព័ន្ធគ្នាដែរ ។ គោលការណ៍សកលភាពមិនពាក់ព័ន្ធថា តើ អវតក អាចអនុវត្តឧក្រិដ្ឋកម្មអន្តរជាតិដែរ ឬយ៉ាងណានោះទេ ។ អត្ថបទយោងបង្ហាញច្បាស់

---

[12] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Akayesu*, ICR-96-4-T សាលក្រមចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ “សាលក្រម” ។

[13] សូមមើលកថាខណ្ឌទី ៨-២០ នៃបណ្តឹងឧទ្ធរណ៍ ។

ថាគោលការណ៍នេះអាចអនុវត្តនៅក្នុងតុលាការជាតិមួយបាន នៅក្នុងករណីដែលបទបញ្ញត្តិនៃច្បាប់ជាតិ អនុញ្ញាតឱ្យរដ្ឋមួយអនុវត្តយុត្តាធិការសកល[14]។ បន្ទាប់មកយុត្តាធិការអាចត្រូវបានទទួលស្គាល់តាមរយៈគោលគោលការណ៍សកលភាព នៅពេលដែលរដ្ឋមួយគ្មានយុត្តាធិការលើជនជាប់ចោទ ។

## ២. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

១០. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី២០ រហូតដល់កថាខណ្ឌទី២៨ ថា ដោយសារតែឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនមែនជាផ្នែកនៃច្បាប់កម្ពុជានៅឆ្នាំ១៩៧៥-១៩៧៩ ដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវតែមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលនៅជាធរមាន បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ពីមូលហេតុដែលពួកគេចាត់ទុកថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលនោះ និងអះអាងថា ការទទួលខុសត្រូវ ត្រូវបានដឹងជាមុន ដោយសារតែវាជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ មេធាវីការពារក្តីមិនបានទាញជាទឡ្ហីករថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងមូលមិនមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់នោះទេ ។ វាមិនមានជាបញ្ហានោះទេ ។ ដូចដែលបានពន្យល់យ៉ាងទូលំទូលាយរួចមកហើយនៅក្នុងបណ្តឹងឧទ្ធរណ៍[15] បញ្ហានៅត្រង់ថាច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនត្រូវបានអនុវត្តដោយផ្ទាល់ក្នុងតុលាការកម្ពុជានៅឆ្នាំ ១៩៧៥-១៩៧៩ ទេ ។ វាតម្រូវឱ្យមានការធ្វើច្បាប់ដើម្បីអនុវត្ត ហើយច្បាប់សម្រាប់អនុវត្តបែបនេះ មិនមាននៅពេលនោះឡើយ។ ដូច្នេះ ការទទួលខុសត្រូវមិនអាចប្រមើលទុកជាមុននៅក្នុងតុលាការកម្ពុជានៅឆ្នាំ១៩៧៥-១៩៧៩ បានទេ ។

១១. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី២៦ ថាគោលការណ៍នីត្យានុកូលភាពមិនបានរាំងមិនឱ្យផ្អែកលើវិធានទំនៀមទម្លាប់មិនសរសេរ ឬមិនឱ្យសម្រេចលើធាតុផ្សំរបស់បទល្មើសមួយតាមរយៈដំណើរការនៃការបកស្រាយ និងការស្រាយបបំភ្លឺទេ ។ ប្រសិនបើកម្ពុជាអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ នោះជាបឋម អង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើធាតុផ្សំនៃបទល្មើស និង

---

[14] Antonio Cassese, *Is the Bell Tolling for Universality? A Plea for a Sensible Notion of Universal Jurisdiction*, 1 J. INT'L CRIM. JUST. 589 (2003).

[15] កថាខណ្ឌទី ១១១-១៤, ១២១-២៥ នៃបណ្តឹងឧទ្ធរណ៍ ។

អំពើល្មើសនីមួយៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានអ្វីខ្លះ ។ ធាតុផ្សំនៃបទល្មើស និងអំពើល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនអាចបកស្រាយ ឬ ស្រាយបំភ្លឺបានទេ ដរាបណាគេមិនទាន់រកឃើញអត្ថិភាពរបស់ពួកវានោះ ។

## ៣. ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ

១២. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី២៩ រហូតដល់កថាខណ្ឌទី៣៦ ថាប្រទេសកម្ពុជានៅពេលវេលាពាក់ព័ន្ធ ជាហត្ថលេខីនៃអនុសញ្ញាក្រុងហ្សឺណែវ ដែលមានចែងនូវបទបញ្ញត្តិនៃការរំលោភយ៉ាងធ្ងន់ធ្ងរ ហើយប្រទេសកម្ពុជាត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយអនុសញ្ញានេះ ។ ពួកគេអះអាងថា ការរំលោភយ៉ាងធ្ងន់ធ្ងរក៏ជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធផងដែរ។ ដោយសារតែឋានៈនៅក្នុងអនុសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៃការរំលោភយ៉ាងធ្ងន់ធ្ងរ ព្រមទាំងចរិតធម្មជាតិនៃភាពឃោរឃៅរបស់វា ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ការទទួលខុសត្រូវអាចព្យាករបាន។ អំណះអំណាងនេះមិនត្រឹមត្រូវ ដូចមូលហេតុពិភាក្សាពីខាងលើរួចមកហើយ ។ កាតព្វកិច្ចរបស់កម្ពុជា ជារដ្ឋមួយ មិនស្មើជាមួយការទទួលខុសត្រូវរបស់បុគ្គលម្នាក់ក្នុងរដ្ឋឡើយ[16] ។ ច្បាប់សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនត្រូវបានអនុវត្តដោយផ្ទាល់នៅកម្ពុជាទេ ។ ពុំមានច្បាប់អនុវត្តនៅពេលនោះទេ[17]។ ដោយសារតែឧក្រិដ្ឋកម្មនៃការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ មិនកើតមាននៅប្រទេសកម្ពុជា ដូច្នេះការទទួលខុសត្រូវនៅតុលាការកម្ពុជា មិនអាចប្រមើលទុលជាមុនបានទេ ។

១៣. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៣១ថា"គោលការណ៍នីត្យានុកូលភាពត្រូវបានបំពេញក្នុងករណីដែលរដ្ឋមួយត្រូវបានចងភ្ជាប់កាតព្វកិច្ចរួចហើយដោយអនុសញ្ញាជាក់លាក់ណាមួយ" ។

---

[16] អនុសញ្ញានីមួយៗក្នុងចំណោមអនុសញ្ញាក្រុងហ្សឺណែវទាំងបួន មានមាត្រាមួយតម្រូវឲ្យរដ្ឋ បង្កើតច្បាប់ជាតិ ដើម្បីធ្វើការផ្តន្ទាទោសប្រឆាំងនឹងមនុស្សដែលប្រព្រឹត្តការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ដោយបានចង្អុលបង្ហាញថាអនុសញ្ញាក្រុងហ្សែណែវមិនមានបំណងអនុវត្តការផ្តន្ទាទោសដោយខ្លួនឯងទេ ។ ប្រទេសកម្ពុជាមិនទាន់បង្កើតច្បាប់បែបហ្នឹងនៅឡើយទេ។ ប្រសិនបើគ្មានច្បាប់សម្រាប់ដាក់ទោសទេ នោះបុគ្គលម្នាក់មិនអាចទទួលខុសត្រូវបទព្រហ្មទណ្ឌចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ នៅក្នុងតុលាការជាតិទេ ។

[17] ដូចខាងលើ នៅកថាខណ្ឌទី ១៩-២០ ។

ជាការគាំទ្រដល់អះអាងនេះ ពួកគេបានសំអាងនូវសាលាក្រមក្នុងរឿងក្ដី ឌុច ។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី ឌុច បានធ្វើឱ្យមានកំហុសក្នុងការសម្រេចនេះ ។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី ឌុច បានលើកមកសំអាងនូវរបាយការណ៍មួយរបស់ក្រុមអ្នកជំនាញ ដែលមិនបានបញ្ជាក់ថាគោលការណ៍នីត្យានុកូលភាព ត្រូវបានបំពេញដែរ ឬអត់ ក្នុងករណីដែលរដ្ឋមួយត្រូវបានចងភ្ជាប់កាតព្វកិច្ចរួចហើយ ដោយអនុសញ្ញាជាក់លាក់ណាមួយនោះ ។ កថាខណ្ឌដែលយោងនៅក្នុងសាលក្រមរឿងក្ដី ឌុច បញ្ជាក់ថា "ប្រទេសកម្ពុជា ឡាវ ថៃឡង់ និងវៀតណាម ជាហត្ថលេខីនៃអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ទាំងបួន ក្នុងអំឡុងពេលដែលពាក់ព័ន្ធ បើទោះបីពុំមានប្រទេសណាមួយក្នុងចំណោមប្រទេសទាំងបួននេះ ជាហត្ថលេខីនៃពិធីសារបន្ថែមឆ្នាំ១៩៧៧ នៅមុនឆ្នាំ១៩៨០ ក៏ដោយ។ ហេតុដូច្នេះ បទបញ្ញត្តិនៃការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវត្រូវតែអនុវត្ត បើទោះបីឧក្រិដ្ឋកម្មមានទំហំធំជាងការរំលោភយ៉ាងធ្ងន់ធ្ងរ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលនោះក៏ដោយ"[18] ។ ក្រុមអ្នកជំនាញត្រូវបានបង្កើតឡើងដោយអនុលោមតាមសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីពិនិត្យមើលជម្រើសនានាដើម្បីនាំមេដឹកនាំខ្មែរក្រហមមកប្រឈមនឹងយុត្តិធម៌ ។ ក្រុមអ្នកជំនាញបានផ្ដល់អនុសាសន៍ឱ្យបង្កើតតុលាការអន្តរជាតិមួយ[19] ។ ទាក់ទងនឹងច្បាប់នៅជាធរមាន អនុសាសន៍ជាច្រើនដែលលើកឡើងនៅក្នុងរបាយការណ៍របស់អ្នកជំនាញមិនបានបញ្ជាក់ពីឋានៈជាតិរបស់ អវតក ទេ ។ គោលការណ៍នីត្យានុកូលភាពនៅក្នុងច្បាប់កម្ពុជាតម្រូវថា ឧក្រិដ្ឋកម្មទាំងអស់ត្រូវបញ្ញត្តិនៅក្នុងច្បាប់ជាតិសិន ទើបច្បាប់ទាំងនោះអាចអនុវត្តបាន[20] ។ ច្បាប់កម្ពុជាមិនមានចែងនូវបទបញ្ញត្តិណាមួយដែលធ្វើឱ្យជាបទល្មើស ចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវនៅឆ្នាំ១៩៧៥-១៩៧៩ ។ ហេតុដូច្នេះ វានឹងរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព បើសិន អវតក យកមកប្រើប្រាស់ដើម្បីផ្ដន្ទាទោសទៅលើការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ។

---

[18] ករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" 00១/១៨-0៧-២00៧-អវតក/អជសដ, សាលក្រមចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ២០០៩ នៅកថាខណ្ឌទី៤០៤ ។

[19] សូមមើលលិខិតដូចគ្នាចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៩៩ ពីលោកអគ្គលេខាធិការផ្ញើរជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ UN Doc No. S/1999/231, p.2 ។

[20] សូមមើលមាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។

00630746



## ខ. បទល្មើសជាតិ

១៤. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៣៨ ថា"ព្រឹត្តិការណ៍ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩និង ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ ត្រូវបានគេដឹងឮយ៉ាងទូលំទូលាយ ថាពុំមានកិច្ចដំណើរការប្រព័ន្ធ យុត្តិធម៌នៅប្រទេសកម្ពុជាទេ ហើយដូច្នេះ បទល្មើសដែលត្រូវចោទប្រកាន់ មិនអាចជំនុំជម្រះ បានទេ"។ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៣៩ ថាអាជ្ញាយុកាលនៃបទល្មើសត្រូវ បានរាំងខានក្នុងអំឡុងឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៣ ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានផ្តល់ការគាំទ្រ ដល់ការអះអាងនេះទេ ។ មេធាវីការពារក្តីបានបង្ហាញ[21] ហើយចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះ សាលាដំបូងក្នុងរឿងក្តី ឌុច បានទទួលស្គាល់[22]ថាមានភស្តុតាងបញ្ជាក់ពីការប្រព្រឹត្តទៅនៃប្រព័ន្ធ តុលាការនាពេលនោះ។

១៥. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៤០ ថាការបន្តអាជ្ញាយុកាលនៃបទល្មើស គឺគ្មាន វិសមិតភាពជាមួយគោលការណ៍គ្មានប្រតិសកម្ម ពីព្រោះវាគ្រាន់តែជាបញ្ហាខាងនីតិវិធី និងមិនផ្ទុយ ពីមាត្រា ១៤ នៃកតិកាសញ្ញា ICCPR ដែរ។ តាមពិតមាត្រា ១៥ នៃកតិកាសញ្ញា ICCPR ទៅវិញ ទេដែលមានចែងនូវបទបញ្ញត្តិនៃគោលការណ៍មិនប្រតិសកម្មនោះ។ ថ្វីបើមានការបន្តអាជ្ញាយុកាល ជាពិសេសបន្ទាប់ពីអាជ្ញាយុកាលរបស់បទល្មើសបានផុតរលត់ ត្រូវបានពិចារណាដោយរដ្ឋជាច្រើន ថាមិនមែនជាបញ្ហាខាងនីតិវិធីទេ ពីព្រោះតែវាមានអនុភាពលើជនជាប់ចោទ ។ ឧទាហរណ៍ ប្រទេសបារាំងមិនអនុញ្ញាតឱ្យបន្តអាជ្ញាយុកាល បន្ទាប់ពីអាជ្ញាយុកាលនៃបទល្មើសបានផុតរលត់[23] តុលាការកំពូលសហរដ្ឋអាមេរិកបានពន្យល់ថា "បន្ទាប់ពី (ប៉ុន្តែមិនមុន) អាជ្ញាយុកាលដើមបាន ផុតរលត់ [ជនជាប់ចោទ] មិនត្រូវផ្តន្ទាទោសឡើយ ។ ហេតុដូច្នេះ ច្បាប់ថ្មីស្តីពីអាជ្ញាយុកាលនៃ បទល្មើសរបស់រដ្ឋកាលីហ្វូញ៉ា "នៅពេលប្រព្រឹត្ត "ត្រូវផ្តន្ទាទោសធ្ងន់ធ្ងរទៅលើបទល្មើសដែលជន ជាប់ចោទត្រូវបានចោទប្រកាន់ ឬធ្វើឱ្យការផ្តន្ទាទោសកាន់តែធ្ងន់ធ្ងរថែមទៀតចំពោះការប្រព្រឹត្ត បទល្មើសកាលពីអតីតកាល [នៅពេលច្បាប់អនុញ្ញាតឱ្យអាជ្ញាយុកាលនៃបទល្មើស ត្រូវបាន

---

[21] សូមមើលបណ្តឹងឧទ្ធរណ៍ នៅកថាខណ្ឌទី ១៧០-៧២ ។

[22] សូមមើល*ករណី កាំង ហ្គេកអ៊ាវ* ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/អជសដ, សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ មេធាវីការពារក្តី ទាក់ទងនឹងអាជ្ញាយុកាលនៃបទល្មើសជាតិ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ២០០៩ ឯកសារ E187 មតិយោបល់របស់ ចៅក្រម Silvia Cartwright និងចៅក្រម Jean-Marc Lavergne នៅកថាខណ្ឌទី៣១-៣៥ ។

[23] សូមមើលបណ្តឹងឧទ្ធរណ៍ នៅកថាខណ្ឌទី ១៦០ ។

អនុម័ត] មិនបង្កើតឲ្យមានការទទួលខុសត្រូវទេនោះ”[24] ។

១៦. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៤១ ថាការគ្មានសេចក្តីសម្រេចក្នុងសម្លេងភាគច្រើនលើបញ្ហានេះនៅក្នុងករណី ០០១ មិនបានរាំងមិនឲ្យអនុវត្តមាត្រា ៣ ថ្មីក្នុងករណី០០២ ដែរ ។ ពួកគេអះអាងថាវាមិនជាបញ្ហាទេដែលថា កសព មិនប្តឹងឧទ្ធរណ៍ចំពោះអង្គហេតុដែលថា ឌុច មិនមានទោសកំហុសចំពោះឧក្រិដ្ឋកម្មជាតិ ។ វាជាការពិតដែលថាសេចក្តីសម្រេចនានាក្នុងករណី ០០១ មិនចងភ្ជាប់កាតព្វកិច្ចក្នុងករណី ០០២ ទេ ។ មេធាវីការពារក្តីមិនបានអះអាងផ្ទុយពីនេះដែរ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះមិនបានអនុវត្តមាត្រា ៣ ថ្មី ហើយ<u>ថែមទាំងមិនបានពិចារណាអំណះអំណាងរបស់មេធាវីការពារក្តី</u> ថាវានឹងរំលោភសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការយកចិត្តទុកដាក់ស្មើគ្នា ។

១៧. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៤១ ថា “ផ្អែកតាមសាលដីកាចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០០៨ លើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា (D99/3/42) អង្គបុរេជំនុំជម្រះបានសម្រេចកែប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ។ ជនជាប់ចោទគួរតែត្រូវបានបញ្ជូនទៅជំនុំជម្រះចំពោះបទល្មើសជាតិ ដើម្បីទប់ស្កាត់ហានិភ័យនៃការសម្រេចឲ្យរួចផុតពីការចោទប្រកាន់នៅសវនាការចំពោះបទចោទដទៃទៀត ។ នេះមិនមែនជាមូលហេតុមានសុពលភាពគតិយុត្តិដើម្បីអនុវត្តច្បាប់ប្រតិសកម្មទេ ដែលនឹងរំលោភបំពានច្បាប់កម្ពុជា និងបទដ្ឋានយុត្តិធម៌អន្តរជាតិ។ ប្រសិនបើច្បាប់មួយមកអនុវត្តដើម្បីចោទប្រកាន់មកលើជនជាប់ចោទម្នាក់ មិនមានអត្ថិភាព ឬពុំមានអត្ថិភាពតទៅទៀត ច្បាប់មិនត្រូវបានបង្កើត ឬ មិនត្រូវមានប្រតិសកម្ម ដើម្បីបំពេញចន្លោះប្រហោងឡើយ ។ម្យ៉ាងវិញទៀត វាមានភាពមិនច្បាស់ថាហេតុអ្វីបានជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថាបើមិនចោទពីបទល្មើសជាតិទេ នោះនឹងមានហានិភ័យនៃការសម្រេចឲ្យរួចផុតពីការចោទប្រកាន់ចំពោះបទល្មើសដទៃទៀត ។ ចំនុចនេះហាក់ដូចជាចង់បញ្ជាក់ន័យថាដើមបណ្តឹងរដ្ឋប្បវេណីទទួលស្គាល់ថា ឧក្រិដ្ឋកម្មអន្តរជាតិប្រហែលជាមិនអាចផ្តន្ទាទោសប្រកបដោយសុពលភាពគតិយុត្តិនោះទេ ។

### គ. សហឧក្រិដ្ឋកម្មរួម

[24] រឿងក្តី *Stogner v. California*, 539 U.S. 607, 613 (2003) ។

១៨. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៤៣ រហូតដល់ ៤៨ ថាសហឧក្រិដ្ឋកម្មរួម (JCE) អាចយកមកប្រើដើម្បីផ្តន្ទាទោសនៅ អវតក ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានញែកឱ្យដាច់ពីគ្នារវាងទម្រង់ខុសៗគ្នានៃ JCE ហើយដើមបណ្តឹងរដ្ឋប្បវេណីហាក់ដូចជាមិនទទួលស្គាល់ថាអង្គបុរេជំនុំជម្រះបានយល់ឃើញរួចមកហើយថា JCEIII មិនអាចយកមកប្រើដើម្បីផ្តន្ទាទោសបានទេ ពីព្រោះ JCEIII មិនមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ១៩៧៥-៧៩។ ដើមបណ្តឹងរដ្ឋប្បវេណីខកខានមិនបានពិចារណាអំណះអំណាងរបស់មេធាវីការពារក្តី ទាក់ទងនឹងកំហុសនៃការលើកអំណះអំណាងពី JCE នៅក្នុងដីកាដំណោះស្រាយ ។ ដើមបណ្តឹងរដ្ឋប្បវេណីហាក់ដូចជាភាន់ច្រឡំការសមគំនិតរបស់ប្រព័ន្ធ common law ជាមួយ JCE[25] ។ ពួកគេមិនបានទទួលស្គាល់ថា ដើម្បីឱ្យទម្រង់នៃនៃការទទួលខុសត្រូវមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការអនុវត្តរបស់រដ្ឋចំពោះទម្រង់នៃការទទួលត្រូវ ត្រូវតែ "ទូលំទូលាយនិងជាក់ស្តែង"[26] ។ ទម្រង់នៃការទទួលខុសត្រូវ JCE មិនត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយនិងជាក់ស្តែងនៅគ្រប់រដ្ឋនោះទេ ។ រដ្ឋមិនបានអនុវត្តទម្រង់នៃការទទួលខុសត្រូវ JCE ក្រៅតែពីការយល់ឃើញរបស់ចៅក្រមដែរ ។ តាមពិត ដើមបណ្តឹងរដ្ឋប្បវេណីបានលើកអំណះអំណាងថា JCE មិនអាចអនុវត្តដើម្បីផ្តន្ទាទោស នៅ អវតក ទេ[27] ។

១៩. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៤៩ ថា "ទម្រង់នៃការទទួលខុសត្រូវពិសេសដែលមានចែងនៅក្នុងមាត្រា២៩ ថ្មី មាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដោយលើកលែងតែការចូលរួមតាមរយៈការធ្វើផែនការ និងទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម ។ យ៉ាងណាក៏ដោយសញ្ញាណនៃការធ្វើផែនការមានបញ្ចូលនៅក្នុងបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយដូច្នេះ គេអាចព្យាករ

---

[25] សូមមើលការអង្កេត នៅកថាខណ្ឌទី ៤៦ ។

[26] រឿងក្តី *North Sea Continental Shelf Cases*, ICJ Reports (1969), នៅកថាខណ្ឌទី 74 ។

[27] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៧-០៩-២០១០-អវតក/កសចស ចម្លើយតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៨ D97/3/4, ERN: 00268488-00268498 ។ *ករណី កាំង ហ្គេកអ៊ាវ* ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២), ចម្លើយតបរបស់សហមេធាវីអន្តរជាតិទៅនឹងសារណារបស់មិត្តតុលាការ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ D99/3/32, ERN: 00239077-00239087 ។ *ករណី កាំង ហ្គេកអ៊ាវ* ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/អជសដ, ប្រតិចារិតនៃដំណើរនីតិវិធីសវនាការជាសាធារណៈនៃរឿងក្តី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៩ E1/78.1, p. 5, l. 25 – p. 6, l. 9 ។

បានថាសកម្មភាពនៃការធ្វើផែនការ អាចបង្កើតបានជាបទល្មើស" ។ ដើមបណ្តឹងរដ្ឋប្បវេណីខកខានមិនបានពន្យល់ថាតើសញ្ញាណនៃការធ្វើផែនការ ត្រូវបានដាក់បញ្ចូលនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដោយវិធីសាស្ត្រអ្វី និងមិននិយាយយោងទៅលើបទបញ្ញត្តិជាក់លាក់ទៀតផង ។ ការទទួលខុសត្រូវតាមទម្រង់នៃការទទួលខុសត្រូវ ដែលមិនមាននៅក្នុងច្បាប់កម្ពុជាដែលនៅជាធរមាននៅឆ្នាំ១៩៧៥-៧៩ ប្រហែលជាមិនអាចព្យាករបានឡើយ ។

## ឃ. ការទទួលខុសត្រូវជាថ្នាក់លើ

២០. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៥១ ថាចារី នៃអំពើរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់អន្តរជាតិក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ។ ថាតើការអះអាងនេះពិតឬមិនពិត ក៏វាមិនមានន័យថាការទទួលខុសត្រូវ តាមរយៈការទទួលខុសត្រូវជាថ្នាក់លើ ជាផ្នែកនៃច្បាប់អន្តរជាតិនៅឆ្នាំ១៩៧៥-៧៩ ដែរ ។

២១. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៥២ ថា "ការទទួលខុសត្រូវជាថ្នាក់លើមានចែងនៅក្នុងមាត្រា ១ នៃអនុសញ្ញា(iv) ការគោរពច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើផ្ទៃដី និងឧបសម្ព័ន្ធរបស់វា..."។ អនុសញ្ញាអាចចែងគោលការណ៍នៃការទទួលខុសត្រូវជាថ្នាក់លើ ប៉ុន្តែ អនុសញ្ញានេះមិនមានចែងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល តាមរយៈការទទួលខុសត្រូវជាថ្នាក់លើ ។ ដូចមេធាវីការពារបានពន្យល់រួចមកហើយ[28] គោលការណ៍នៃការទទួលខុសត្រូវចំពោះការបង្គាប់បញ្ជាមិនស្មើគ្នានឹងការទទួលខុសត្រូវជាថ្នាក់លើទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានអះអាងថាការទទួលខុសត្រូវជាថ្នាក់លើដែលមានចែងនៅក្នុងមាត្រា ៤៣(១) នៃពិធីសារបន្ថែម I[29] ។ ជាថ្មីម្តងទៀត មាត្រា ៤៣(១) យោងទៅលើគោលការណ៍នៃការទទួលខុសត្រូវជាថ្នាក់លើ

---

[28] សូមមើលបណ្តឹងឧទ្ធរណ៍ នៅកថាខណ្ឌ២៨៥-៨៦ ។ *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៧-០៩-២០១០-អវតក/កសចស(អបជ៧៥), ចម្លើយតបរបស់ អៀង សារី ចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់អៀង សារី នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ ("ចម្លើយតបទៅនឹងចម្លើយតបរបស់ កសព") នៅកថាខណ្ឌទី ១១៤ ។

[29] វិធីសារបន្ថែម I ចំពោះអនុសញ្ញាក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងវិធីសារស្តីពីការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធ ("វិធីសារបន្ថែម I") ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៨៧ ។

ជាជាងការទទួលខុសត្រូវជាថ្នាក់លើ ។ តាមពិតមាត្រា ៨៦ និងមាត្រា ៨៧ នៃវិធីសារបន្ថែម I ដែលពេលនេះត្រូវបានគេពិចារណាធ្វើចំណាត់ថ្នាក់ជាការទទួលខុសត្រូវជាថ្នាក់លើវិញ ។ ប៉ុន្តែ វិធីសារបន្ថែម I មិនចងភ្ជាប់កាតព្វកិច្ចកម្ពុជានៅឆ្នាំ១៩៧៥-៧៩ ទេ ហើយក៏មិនបានដាក់ចូលជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលនោះដែរ[30] ។

២២. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងនៅកថាខណ្ឌទី៥៣ ថា "ចំនុចនេះក៏អនុវត្តចំពោះជម្លោះប្រដាប់អាវុធផ្ទៃក្នុងប្រទេសដែរ ។ សញ្ញាណនៃការទទួលខុសត្រូវជាថ្នាក់លើមិនមែនជាផ្នែកស្នូលនៃការរារាំង មិនឱ្យប្រព្រឹត្តនូវអំពើជាក់លាក់ក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធផ្ទៃក្នុងប្រទេស ដែលមានចែងនៅក្នុងមាត្រា ៣ រួមនៃអនុសញ្ញាក្រុងហ្សឺណែវ" ។ ការទទួលខុសត្រូវថ្នាក់លើ ជាសញ្ញាណនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល មិនមែនមាននៅក្នុងអនុសញ្ញាក្រុងហ្សឺណែវទេ ។ ប្រសិនបើវិធីសារបន្ថែម I កើតចេញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-៧៩ នោះមែន ដូច្នេះវិធីសារបន្ថែម I អនុវត្តបានតែជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ។ វិធីសារបន្ថែម II[31] ដែលអនុវត្តចំពោះជម្លោះប្រដាប់អាវុធផ្ទៃក្នុងប្រទេស មិនមានបទបញ្ញត្តិស្រដៀងគ្នានេះទេ[32] ។

២៣. ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងកថាខណ្ឌទី៥៥ ថា"មេធាវីការពារក្តីក៏បានអះអាងផងដែរថាការទទួលខុសត្រូវជាថ្នាក់លើអនុវត្តតែទៅលើឧក្រិដ្ឋកម្មសង្គ្រាមប៉ុណ្ណោះ"។ ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ការទទួលខុសត្រូវជាថ្នាក់លើអនុវត្តចំពោះឧក្រិដ្ឋកម្មសង្គ្រាម ព្រោះពួកគេបានអះអាងថាការទទួលខុសត្រូវជាថ្នាក់លើ ក៏អាចយកទៅអនុវត្តលើមន្ត្រីស៊ីវិល និងមេបញ្ជាការយោធាផងដែរ[33]។ វាមានភាពមិនច្បាស់ទេថា តើហេតុអ្វីបានជាការយកមកប្រើប្រាស់ដើម្បីផ្តន្ទាទោសចំពោះការទទួលខុសត្រូវជាថ្នាក់លើប្រឆាំងនឹងមេដឹកនាំស៊ីវិល តម្រូវឱ្យមានការពង្រីកមិនត្រឹមតែបទឧក្រិដ្ឋធម្មតាប៉ុណ្ណោះទេ ប៉ុន្តែឧក្រិដ្ឋកម្មសង្គ្រាមផងដែរ។ តាម

[30] សូមមើលបណ្តឹងឧទ្ធរណ៍ នៅកថាខណ្ឌ២៨៥-២៨៦ ។ ចម្លើយតបទៅនឹងចម្លើយតបរួមរបស់ កសព នៅកថាខណ្ឌទី១២១-១២២ ។

[31] វិធីសារបន្ថែមចំពោះអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងវិធីសារបន្ថែមស្តីពីការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនអន្តរជាតិ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ ("វិធីសារបន្ថែម II")

[32] សូមមើលបណ្តឹងឧទ្ធរណ៍ នៅកថាខណ្ឌទី៣០៨ ។

[33] ចម្លើយតប, កថាខណ្ឌទី៥៨ ដល់៥៩។

ពិតរាល់ទឡ្ហីករដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាំទ្រអត្ថិភាពនៃការទទួលខុសត្រូវថ្នាក់លើនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាក់ទងតែទៅនឹងឧក្រិដ្ឋកម្មសង្គ្រាមប៉ុណ្ណោះ[34]។

២៤. ប្រការដែលថាលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូហ្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ចែងថាការទទួលខុសត្រូវជាថ្នាក់លើចំពោះមេដឹកនាំជនស៊ីវិល គឺមិនមានអានុភាពទៅលើបញ្ហាថាតើទម្រង់នៃការទទួលខុសត្រូវបែបនេះមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែរឬអត់ទេ ដោយមិននិយាយទៅដល់ច្បាប់កម្ពុជាពីឆ្នាំ១៩៧៥-៧៩ ដែលមានជាយូរមកហើយនៅមុនបង្កើតតុលាការអន្តរជាតិទាំងនោះទៀតផង ។

## ខ. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌

២៥. ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងក្នុងកថាខណ្ឌទី៦០ ដល់៦២ ថាមេធាវីការពារក្តីខកខានមិនបានបង្ហាញពីការរំលោភសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះទេ ។ ការលើកឡើងបែបនេះមិនត្រឹមត្រូវទេ ។ យ៉ាងហោចណាស់ដីកាដំណោះស្រាយបានរំលោភសិទ្ធិខាងក្រោមនេះ៖

ក. សិទ្ធិរបស់លោក អៀង សារី ក្នុងការសន្មតទុកជាមុនថាគ្មានទោស[35]

ខ. សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា[36]

គ. សិទ្ធិរបស់លោក អៀង សារី ក្នុងការត្រៀមរៀបចំការការពារក្តី[37]

ឃ. សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការការពារប្រឆាំងនឹងការកាត់ក្តីពីរ

---

[34] ដើមបណ្តឹងរដ្ឋប្បវេណី ដកស្រង់៖ មាត្រា១នៃអនុញ្ញា(IV) ការគោរពច្បាប់ និងទំនៀមទម្លាប់សង្គ្រាមជើង គោក និងឧបសម្ព័ន្ធរបស់វា (ក្នុងចម្លើយតប, កថាខណ្ឌទី៥២) និងផ្តល់ទឡ្ហីករណ៍ថា "ការជំនុំជម្រះក្តីក្នុងតុលាការក្រុងតូក្យូ មន្ត្រីស៊ីវិលមួយចំនួន ត្រូវបានផន្ទាទោសពីឧក្រិដ្ឋកម្មសង្គ្រាម អនុលោមតាមទ្រឹស្តីការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ" ។ចម្លើយតប, កថាខណ្ឌទី៥៩ (គូសបញ្ជាក់បន្ថែម)។

[35] សូមមើលបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី២១ ដល់២២, ៤០ និង១៧៤ ដល់១៧៥។

[36] ដូចគ្នា, កថាខណ្ឌទី១៥៤ ដល់១៥៧។

[37] ដូចគ្នា, បើក, កថាខណ្ឌទី៣។

00630752



ផង[38]

ច. សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់[39] និង

ឆ. សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការមិនអនុវត្តច្បាប់ជាប្រតិសកម្ម[40]

**ច. ការលើកលែងទោស និងការមិនជំនុំជម្រះពីរដង** *(ne bis in idem)*

២៦. ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនៅក្នុងកថាខណ្ឌទី៦៣ ថាមាត្រា១៤(៧)នៃ ICCPR បានចែងពីគោលការណ៍មិនជំនុំជម្រះពីរដង *(ne bis in idem)* ។ នេះជាលើកលើកឡើងត្រឹមត្រូវ ហើយគោលការណ៍នេះក៏មាននៅក្នុងមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផងដែរ ដែលមិនបានចែងពីការលើកលែងណាមួយនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថាគោលបំណងនៃគោលការណ៍នេះ គឺដើម្បី"ធានាថាបុគ្គលម្នាក់ៗមិនត្រូវបានគេគាបសង្កត់ខាងរូបកាយ ខាងផ្លូវអារម្មណ៍ ចិត្តសាស្ត្រ ឬផ្នែកហិរញ្ញវត្ថុជាច្រើនលើកច្រើនសារចំពោះបទល្មើសដដែលឡើយ" ។ នេះមិនមែនជាគោលបំណងតែមួយគត់របស់គោលករណ៍នេះទេ ។ គោលការណ៍មិនជំនុំជម្រះពីរដង "ត្រូវបានគេចាត់ទុកថាមានលក្ខណៈស្រដៀងគ្នានឹង ការទទួលស្គាល់អានុភាពនៃអាជ្ញាអស់ជំនុំរបស់សេចក្តីសម្រេចដទៃទៀត ដែលមានគោលដៅការពារការវិនិច្ឆ័យចុងក្រោយ។ គំនិតនេះគឺថានៅពេលដែលរឿងក្តីមួយត្រូវបានដោះស្រាយរួចស្រេចហើយ រឿងក្តីនោះមិនត្រូវលើកយកមកជំនុំជម្រះម្តងទៀតឡើយ (*factum praeteritum*) ព្រោះវាអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការគោរពនីតិវិធីតុលាការ និងអំណាចតុលាការជាទូទៅ[41] "។ ករណីនេះត្រូវបានគេពិពណ៌នាថាជា "ឥទ្ធិពលខាងនីតិវិធី" នៃគោលការណ៍មិនជំនុំជម្រះពីរដង[42]។ សេចក្តីត្រូវការរបស់ អវតក

---

[38] ដូចគ្នា, កថាខណ្ឌទី២១ ដល់៤១។

[39] ដូចគ្នា, កថាខណ្ឌទី១០៣ ដល់១៣៥។

[40] ដូចគ្នា, កថាខណ្ឌទី១៣៨ ដល់១៧៩។

[41] ករណី YASMIN Q NAQVI, ការរាំងដល់ការអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ, កថាខណ្ឌទី ៣០៧ ដល់ ៣០៨ (T.M.C. Asser Press 2010) ។

[42] ដូចគ្នា, កថាខណ្ឌទី២៩២ ដល់២៩៣។

ដើម្បីធ្វើជាតុលាការគំរូនៅកម្ពុជា[43] និងដើម្បីបង្កើនការគោរពអំណាច និងនីតិវិធីតុលាការ អវតក ត្រូវតែបង្ហាញពីការគោរព និងអនុវត្តគោលការណ៍មិនជំនុំជម្រះពីរដង ។

២៧. ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនៅក្នុងកថាខណ្ឌទី៦៥ ថាការជំនុំជម្រះក្តីរបស់លោក អៀង សារី កាលពីឆ្នាំ១៩៧៩ គឺមិនស្របទៅនឹងបទដ្ឋានអន្តរជាតិឡើយ ដោយបានបញ្ជាក់ថាគោលការណ៍មិនជំនុំជម្រះពីរដង មិនអាចយកមកអនុវត្តដើម្បីរារាំងមិនឱ្យកាត់ក្តីលោក អៀង សារី នៅពេលបច្ចុប្បន្ននេះបានឡើយ។ ទី១ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានផ្តល់នូវការគាំទ្រណាមួយឡើយចំពោះអំណះអំណាងរបស់ពួកគេដែលថាការកាត់សេចក្តីនៅឆ្នាំ១៩៧៩ មិនបានឆ្លើយតបទៅនឹង "បទដ្ឋានអន្តរជាតិ"។ ទី២ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានចែងពីករណីលើកលែងចំពោះគោលការណ៍មិនជំនុំជម្រះពីរដងឡើយ[44]។ ទោះបីជាគេរកឃើញថាមានករណីលើកលែងនេះក៏ដោយ ក៏គោលបំណងនៃករណីលើកលែងនេះ នៅតែដើម្បីទប់ស្កាត់ការកាត់ក្តីក្លែងក្លាយ ដែលធ្វើឡើងដើម្បីបិទបាំងការទទួលខុសត្រូវរបស់ជនជាប់ចោទ[45]។ ការជំនុំជម្រះក្តីកាលពីឆ្នាំ១៩៧៩ បង្កើតនូវការផ្តន្ទាទោសប្រហារជីវិត ។ វាមិនមែនជាការជំនុំជម្រះក្តីក្លែងក្លាយដើម្បីជួយឱ្យលោក អៀង សារី ឱ្យរួចផុតពីការទទួលខុសត្រូវឡើយ ។

២៨. ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនៅក្នុងកថាខណ្ឌទី៦៦ ថាបទល្មើសដែលលោក អៀង សារី ត្រូវបានលើកលែងទោស គឺមិនដូចជាបទល្មើសដែលមានក្នុងដីកាដំណោះស្រាយនោះទេ ព្រោះលោក អៀង សារី ទទួលបានការលើកលែងទោសចំពោះការចោទប្រកាន់ក្រោមច្បាប់ឆ្នាំ ១៩៩៤ ។ ដើមបណ្តឹងរដ្ឋប្បវេណី មិនបានពន្យល់ថាតើពួកគេចាត់ទុកបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់ឆ្នាំ១៩៩៤ ថាខុសគ្នាពីបទឧក្រិដ្ឋដែលបានចោទប្រកាន់នៅពេលថ្មីៗនេះយ៉ាងដូម្តេចនោះទេ ។ ដូចដែលមេធាវីការពារក្តីបានពន្យល់រួចមកហើយថា លោកអៀង សារី ទទួលបានការលើកលែងទោសចំពោះការ

---

[43] "អវតក ត្រូវបានបង្កើតឡើងដើម្បីធ្វើជាតុលាការគំរូដល់កំណែទម្រង់តុលាការ និងច្បាប់នៅកម្ពុជា"។ អនុសាសន៍ផ្សេងៗទាក់នឹងតម្លាភាពបន្ថែមនៅ អវតក ដែលលើកឡើងដោយសមាជិកអង្គការសង្គមស៊ីវិល និងសមាជិកសារព័ត៌មានកម្ពុជា, ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៨, សូមចូលទៅក្នុង http://www.cambodiatribunal.org/CTM/Recommendations%20Regarding%20Additional%Transparency.pdf?phpMyAdmin=8319ad34ce0db941ff04d8c788f6365e.

[44] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា១២។

[45] សូមមើលករណី អៀង សារី,សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-កសចស,ដីកាឃុំខ្លួនបណ្តោះ អាសន្ន, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, C22, ERN:00153253-00153260,កថាខណ្ឌទី៨។

ចោទប្រកាន់នៅពេលថ្មីៗនេះទាំងអស់[46]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានលើកឡើងផងដែរថាការលើកលែងទោសលោក អៀង សារី អនុវត្តតែទៅលើទោសប្រហារជីវិត និងការរឹបអូសទ្រព្យសម្បត្តិប៉ុណ្ណោះ ប៉ុន្តែមិនអនុវត្តចំពោះបទល្មើសដែលគាត់បានប្រព្រឹត្តឡើយ ។ ការលើកឡើងបែបនេះមិនត្រឹមត្រូវទេ ។ នៅពេលលោក អៀង សារី ត្រូវបានលើកលែងទោស ប្រទេសកម្ពុជាបានលុបទោសប្រហារជីវិតរួចទៅហើយ[47]។ ដូច្នេះ វាច្បាស់ណាស់ថាព្រះមហាក្សត្រប្រទានការលើកលែងទោសនេះ គឺមិនគ្រាន់តែដើម្បីធានាថាទោសប្រហារជីវិត នឹងមិនត្រូវគេអនុវត្តប្រឆាំងលោក អៀង សារី ប៉ុណ្ណោះ។ ព្រះមហាក្សត្រអាចដឹងថាវានឹងមិនចាំបាច់ទេក្នុងការប្រទានការលើកលែងទោសចំពោះអ្វីដែលរដ្ឋធម្មនុញ្ញបានហាមឃាត់រួចនោះទេ។ ប៉ុន្តែព្រះមហាក្សត្របានប្រទានការលើកលែងទោសនេះ ។ ព្រះមហាក្សត្រប្រាកដជាចង់ធានាថាលោក អៀង សារី នឹងមិនបំរើទោសណាមួយទាក់ទងទៅនឹងការវិនិច្ឆ័យទោស ដោយផ្អែកលើបទល្មើសដែលជាកម្មវត្ថុនៃការជំនុំជម្រះក្តីក្នុងឆ្នាំ១៩៧៩ ឡើយ ។ ព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រមិនត្រូវបានគេរំលោភបំពានតាមវិធីមួយដែលអាចធ្វើឲ្យព្រះរាជក្រឹត្យទាំងនោះមើលទៅមិនសំខាន់ឡើយ ។

២៩. ចុងបញ្ចប់ ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថាបទល្មើសដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ មានឋានៈជាវិធានដាច់ខាត *jus congens* ក្រោមច្បាប់អន្តរជាតិ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានពន្យល់ថាឋានៈនេះមានឥទ្ធិពលអ្វីនោះទេ។ ច្បាប់កម្ពុជា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនបានហាមឃាត់ការលើកលែងទោសចំពោះបទឧក្រិដ្ឋតាមវិធានដាច់ខាតឡើយ[48]។

ដូច្នេះ យោងតាមមូលហេតុដែលបានគូសបញ្ជាក់នៅក្នុងសំណើ មេធាវីការពារក្តីស្នើសុំដោយសេចក្តីគោរពដល់អង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍ និងសម្រេចតាមការស្នើសុំ ។

---

[46] សូមមើលបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី៨៤ ដល់៨៥។

[47] ដូចគ្នា, កថាខណ្ឌទី៨០។

[48] ដូចគ្នា, កថាខណ្ឌទី៧០ ដល់៨២, ចម្លើយតបទៅកាន់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣០ ដល់៣១។

00630755

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អបជ ៧៥)
លេខ/No: D427/1/24

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកចម្លើយតបនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១០

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**